## **<u>កម្មវិធីអប់រំបណ្ដោះអាសន្ន</u>**

## **<u>ការអធិប្បាយអំពីកម្មវិធី</u>**

កម្មវិធីអប់រំបណ្ដោះអាសន្ននេះ បង្កើតឱ្យមានភាពងាយស្រួលដល់សិស្ស និយាយភាសាអង់គ្លេស ដែលមិនមែនជាភាសាកំណើតរបស់ខ្លួននៅក្នុងការចេះអាននិងសរសេរភាសាអង់គ្លេស និង ភាសាកំណើតរបស់ខ្លួន។ កម្មវិធីនេះ ក៏ជួយដល់សិស្សទទួលជោគជ័យផងដែរលើវិញ្ញាសារសិក្សានានា។ កម្មវិធីនេះ ផ្ដោតជាសំខាន់ទៅលើការអភិវឌ្ឍន៍ទ្វេរភាសានិយមដ៏ពេញលេញ។ ខ្លឹមសារសិក្សា មានទិសដៅឆ្ពោះទៅរកការលើកកំពស់កំរិតយល់ដឹង និង ធ្វើឱ្យចេះអាននិងសរសេរជាទ្វេរភាសា។

**ទិសដៅអប់រំ:** គឺដើម្បីសំរេចបាននូវជោគជ័យក្នុងការសិក្សាទៅតាមបទដ្ឋាន សំរាប់លើកកំពស់ការយល់ដឹង (ដំឡើងថ្នាក់) និង ធ្វើឱ្យចេះអាននិងសរសេរជាទ្វេរភាសា។

**សមាសភាគនានានៃកម្មវិធីសិក្សា:** បុត្រធីតារបស់លោកអ្នក នឹងទទួលបានការអប់រំលើមុខវិជ្ជានានាដែលបានគូសយកដូចខាងក្រោមនេះ :

**ថ្នាក់រៀនជាភាសាអង់គ្លេសសុទ្ធ:**

| | | | |
|---|---|---|---|
| _____ | ការបង្ហាត់ជំនាញភាសាអង់គ្លេសជាភាសាទី២ | _____ | ប្រវត្តិសាស្ត្រអាមេរិកាំង |
| _____ | ការអាននិងសរសេរជាភាសាអង់គ្លេស | _____ | ជំនាញសំខាន់ៗសំរាប់ជីវភាពប្រចាំថ្ងៃ |
| _____ | គណិតវិទ្យា | _____ | សុខភាពនិងអនាម័យ |
| _____ | ការសិក្សាអំពីសង្គម | _____ | អប់រំអំពីការបើកបរ |

**ថ្នាក់រៀនជាភាសាកំណើតរបស់បុត្រធីតាលោកអ្នក:**

| | | | |
|---|---|---|---|
| _____ | ការបង្ហាត់ជំនាញភាសាអង់គ្លេសជាភាសាទី២ | _____ | ប្រវត្តិសាស្ត្រអាមេរិកាំង |
| _____ | ការអាននិងសរសេរជាភាសាអង់គ្លេស | _____ | ជំនាញសំខាន់ៗសំរាប់ជីវភាពប្រចាំថ្ងៃ |
| _____ | គណិតវិទ្យា | _____ | សុខភាពនិងអនាម័យ |
| _____ | ការសិក្សាអំពីសង្គម | _____ | អប់រំអំពីការបើកបរ |

**ទំរង់បែបបទប្រឡងចេញ (ពត៌មាននៅផ្នែកនេះ ខុសគ្នាពីកន្លែងមួយទៅកន្លែងមួយ)**

សិស្សត្រូវរៀននៅក្នុងកម្មវិធីបណ្តោះសន្ននេះរយៈពេល៣ ឬរហូតដល់ពួកគេសំរេចបានជោគជ័យជំនាញភាសាអង់គ្លេស។ អត្រារំពឹងទុកបណ្តោះអាសន្ន របស់មូលដ្ឋានយើងភាគច្រើនគឺ ____ ភាគរយ (%) ក្នុងមួយឆ្នាំៗ។

អត្រារំពឹងទុកអំពីការបញ្ចប់ការសិក្សានៅវិទ្យាល័យនៅក្នុងកម្មវិធីនេះ គឺ ____ ។

**សេវាកម្មអប់រំពិសេសៗ**

សំរាប់សិស្សពិការដែលត្រូវការសេវាជំនាញ ការអប់រំផ្នែកភាសាបានឆ្លើយតបទៅតាមទិសដៅនៃកម្មវិធីអប់រំដាច់ៗដោយឡែកពីគ្នា (ការបង្រៀនសិស្សតែម្នាក់ៗ - គ្រូ១ សិស្ស១)។

**កម្មវិធីផ្សេងៗទៀតដែលបានផ្តល់ឱ្យនៅឯសាលា**

- ការបង្រៀនយ៉ាងទៀងទាត់ដល់សិស្សដែលនិយាយភាសាអង់គ្លេសបានល្អ។ ការបង្រៀននេះប្រើប្រាស់ភាសាអង់គ្លេសពេញម៉ោងទាំងអស់។ ភាសាកំណើត មិនត្រូវគេប្រើប្រាស់នៅក្នុងម៉ោងបង្រៀននោះទេ។ មិនមានភាសាអង់គ្លេសដែលចាត់ទុកជាការបង្រៀនភាសាទី២ត្រូវបានផ្តល់ឱ្យសំរាប់កម្មវិធីសិក្សានោះទេ។ ទិសដៅអប់រំនេះ គឺដើម្បីឆ្លើយតបទៅនឹងកំរិតបទដ្ឋានសំរេចជោគជ័យនៅក្នុងការសិក្សាត្រឹមត្រូវ សំរាប់ការឡើងថ្នាក់ និង បញ្ចប់ការសិក្សានៅសាលានេះ។

- ព័ត៌មានបន្ថែមអំពីកម្មវិធីសិក្សាផ្សេងទៀតដែលបានផ្តល់ឱ្យនោះ អាចមានភ្ជាប់មកជាមួយ។